01036596

E314/12

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 14 / 11 / 2014
ម៉ោង (Time/Heure) : 15:15
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Sann Rada

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

| | |
|---|---|
| ចំពោះមុខ: | ចៅក្រម **និល នន្ទ** ជាប្រធាន |
| | ចៅក្រម **Rowan DOWNING** |
| | ចៅក្រម **Chang-ho CHUNG** |
| | ចៅក្រម **យ៉ា សុខន** |
| | ចៅក្រម **យូ អុត្តារ៉ា** |
| កាលបរិច្ឆេទ: | ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១៤ |
| ភាសាដើម: | ខ្មែរ/អង់គ្លេស/បារាំង |
| ចំណាត់ថ្នាក់ឯកសារ: | សាធារណៈ |

## សេចក្តីសម្រេចលើបណ្តឹងជំទាស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូង

**សហព្រះរាជអាជ្ញា**

ជា លាង

Nicholas KOUMJIAN

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ

Marie GUIRAUD

**ជនជាប់ចោទ**

នួន ជា

ខៀវ សំផន

**មេធាវីជនជាប់ចោទ**

សុន អរុណ

Victor KOPPE

គង់ សំអុន

Arthur VERCKEN
Anta GUISSÉ

**ក្រុមប្រឹក្សាជំនុំជម្រះពិសេស** នៃអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("ក្រុមប្រឹក្សាជំនុំជម្រះពិសេស") បានទទួលពាក្យបណ្តឹងរបស់មេធាវីការពារក្តី ខៀវ សំផន ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៤ ប្តឹងជំទាស់ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះ ចៅក្រម Silvia CARTWRIGHT ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc LAVERGNE ចៅក្រម យូរ ឧត្តរា និង ចៅក្រម Claudia FENZ មិនឱ្យជំនុំជម្រះទៅលើសំណុំរឿង ០០២/០២ (ពាក្យបណ្តឹងរបស់ ខៀវ សំផន)[1] ពាក្យបណ្តឹងរបស់មេធាវីការពារក្តី នួន ជា ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ ប្តឹងជំទាស់ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះ ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc LAVERGNE និងចៅក្រម យូរ ឧត្តរា ចេញពីកិច្ចដំណើរការនីតិវិធីតទៅមុខទៀតប្រឆាំងនឹង នួន ជា (ពាក្យបណ្តឹងរបស់ នួន ជា)[2] និងពាក្យបណ្តឹងជំទាស់ចៅក្រមសាជាថ្មីរបស់មេធាវីការពារក្តី ខៀវ សំផន ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៤ ស្នើសុំបញ្ចូលទឡ្ហីករណ៍ផ្សេងៗដែលមាននៅក្នុងពាក្យបណ្តឹងរបស់ នួន ជា ដើម្បីគាំទ្រពាក្យបណ្តឹងទីមួយរបស់មេធាវី ខៀវ សំផន ដោយលើកលែងចំពោះលោកស្រីចៅក្រម Silvia CARTWRIGHT ដែលនៅពេលនោះលែងជាចៅក្រមនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទៀតហើយ (ពាក្យបណ្តឹងជំទាស់ចៅក្រមសាជាថ្មី)[3]។

**ក្រោយពីកត់សម្គាល់ឃើញថា** ការិយាល័យសហព្រះរាជអាជ្ញា (ក.ស.ព) បានដាក់ចម្លើយតបជំទាស់ទៅនឹងពាក្យបណ្តឹងរបស់ ខៀវ សំផន និង នួន ជា[4]។

**ក្រោយពីបានទទួល** សំណើរបស់ ក.ស.ព សុំឱ្យមានសេចក្តីសម្រេចឱ្យបានឆាប់រហ័សទៅលើបណ្តឹងជំទាស់ចៅក្រម ដោយក្នុងសំណើនោះ ក.ស.ព បានស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះពិសេសចេញ

[1] សំណើរបស់លោក ខៀវ សំផន សុំឱ្យពិនិត្យឡើងវិញពីភាពចាំបាច់ក្នុងការរង់ចាំសាលក្រមក្នុងសំណុំរឿង ០០២/០១ ចូលជាស្ថាពរ មុននឹងចាប់ផ្តើមការជំនុំជម្រះសំណុំរឿង ០០២/០២ និងសុំឱ្យពិនិត្យឡើងវិញពីការចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះថ្មីមួយ ឯកសារ E314/1 ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៤។

[2] បណ្តឹងជំទាស់ចៅក្រមរបស់ នួន ជា ប្រឆាំងនឹងចៅក្រម និល ណុន ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc LAVERGNE និងចៅក្រម យូរ ឧត្តរា ឯកសារ E314/6 ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤។

[3] បណ្តឹងជំទាស់ចៅក្រមសាជាថ្មីប្រឆាំងនឹងសមាសភាពចៅក្រមបច្ចុប្បន្ននៃអង្គជំនុំជម្រះសាលាដំបូងដែលត្រូវសម្រេចលើសំណុំរឿង ០០២/០២ ឯកសារ E314/8 ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៤។

[4] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ ខៀវ សំផន សុំផ្អាកកិច្ចដំណើរការនីតិវិធី ឬប្តឹងជំទាស់ចៅក្រម ឯកសារ E314/3 ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១៤។ ចម្លើយតបរបស់សហព្រះរាជអាជ្ញាចំពោះបណ្តឹងជំទាស់ចៅក្រមរបស់ នួន ជា ឯកសារ E314/9 ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៤។

សេចក្តីសម្រេចរបស់ខ្លួនទៅលើបណ្តឹងជំទាស់នេះឲ្យបានឆាប់រហ័សតាមអាចធ្វើទៅបានដោយផ្តល់សំអាងហេតុតាមក្រោយ[5]។

**ក្រោយពីកត់សម្គាល់ឃើញថា** នៅក្នុងការធ្វើសេចក្តីសន្និដ្ឋានបើកការចោទប្រកាន់ក្នុងសំណុំរឿង ០០២/០២ កាលពីថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៤ ជនជាប់ចោទ នួន ជា បានលើកឡើងនូវបញ្ហាមួយចំនួនដោយរួមទាំងការណែនាំឲ្យមេធាវីការពារក្តីរបស់គាត់មិនឲ្យចូលរួមនៅក្នុងសវនាការរបស់អង្គជំនុំជម្រះសាលាដំបូងនាពេលខាងមុខប្រឆាំងនឹងរូបគាត់ ក្នុងអំឡុងពេលរង់ចាំសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះពិសេសទៅលើពាក្យបណ្តឹងជំទាស់ដែលបានដាក់ដោយមេធាវីការពារក្តីរបស់គាត់[6]។

**ដោយរម្លឹកឡើងវិញថា** នៅថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៤ ក្រុមប្រឹក្សាជំនុំជម្រះពិសេសបានជូនដំណឹងទៅភាគីនានាថា ខ្លួនបដិសេធមិនធ្វើសវនាការដើម្បីស្តាប់ទឡ្ហីករណ៍ផ្ទាល់មាត់របស់ភាគីទេ ប៉ុន្តែអនុញ្ញាតឲ្យមេធាវីការពារក្តី នួន ជា ដាក់សារណាតបជាលាយលក្ខណ៍អក្សរទៅនឹងចម្លើយតបរបស់ ក.ស.ព យ៉ាងយូរបំផុតត្រឹមថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤។ ក្រុមប្រឹក្សាជំនុំជម្រះពិសេសបានណែនាំថា ការឆ្លើយតបនោះត្រូវកំហិតត្រឹមតែបញ្ហាថ្មីៗដែលត្រូវបានលើកឡើងក្នុងចម្លើយតបរបស់ ក.ស.ព ប៉ុណ្ណោះ ប្រសិនបើមាន[7]។

**ក្រោយពីកត់សម្គាល់ឃើញថា** នៅថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤ មេធាវីការពារក្តី នួន ជា បានជូនដំណឹងដល់ក្រុមប្រឹក្សាជំនុំជម្រះពិសេសតាមរយៈអ៊ីម៉ែលថា ខ្លួនមិនមានបំណងដាក់សារណាតបជាលាយលក្ខណ៍អក្សរទេ[8]។

---

[5] សំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យមានសេចក្តីសម្រេចឆាប់រហ័សលើបណ្តឹងជំទាស់ចៅក្រម ឯកសារ E314/10 ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៤។ ក្រុមប្រឹក្សាជំនុំជម្រះពិសេសបានកត់សម្គាល់ថា អត្ថបទបកប្រែជាភាសាខ្មែរនៃចម្លើយតបរបស់ ក.ស.ព ទៅនឹងពាក្យបណ្តឹងរបស់ នួន ជា ត្រូវបានផ្តល់ឲ្យនៅថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៤។

[6] ប្រតិចារឹកសវនាការ ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ E1/242.1 ទំព័រ ៥២៖ "ប្រសិនបើលោកចៅក្រមមិនផ្អាកសវនាការក្នុងខណៈពេលបណ្តឹងជំទាស់ កំពុងពិនិត្យសេចក្តី -- កំពុងពិនិត្យ និងសម្រេចនោះ លោកចៅក្រមធ្វើឲ្យខ្ញុំគ្មានជម្រើសផ្សេងទេ។ ខ្ញុំសូមណែនាំ និងស្នើសុំមេធាវីរបស់ខ្ញុំឲ្យចេញពីបន្ទប់សវនាការ បន្ទាប់ពីលោក ខៀវ សំផន ប្រកាសពីជំហររបស់គាត់ ហើយនឹងពហិកាមិនចូលរួមរាល់សវនាការនាពេលខាងមុខនៃសវនាការលើកទី២នេះ រហូតដល់បណ្តឹងជំទាស់ត្រូវបានសម្រេច"។

[7] អ៊ីម៉ែលពីក្រឡាបញ្ជីនៃក្រុមប្រឹក្សាជំនុំជម្រះពិសេសទៅកាន់ភាគី ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៤។

[8] អ៊ីម៉ែលពីទីប្រឹក្សាច្បាប់របស់មេធាវីការពារក្តី នួន ជា ទៅកាន់ក្រឡាបញ្ជីនៃក្រុមប្រឹក្សាជំនុំជម្រះពិសេស ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤។

**ក្រោយពីកត់សម្គាល់ឃើញថា** ចៅក្រម Silvia CARTWRIGHT លែងជាចៅក្រមនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចាប់ពីថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៤ ទៀតហើយ។

**ក្រោយពីកត់សម្គាល់ឃើញថា** មិនមានចៅក្រមណាមួយក្នុងចំណោមចៅក្រមដែលត្រូវបានប្តឹងជំទាស់ មានបំណងដាក់សារណាជាលាយលក្ខណ៍អក្សរ អនុលោមតាមវិធាន ៣៤ (៧) នៃវិធានផ្ទៃក្នុង។

**ក្រោយពីបានពិភាក្សាសម្រេច** ទៅលើសារណានានារបស់ភាគី និងទៅលើពាក្យបណ្តឹងរបស់ ខៀវ សំផន និង នួន ជា។

**ដោយយល់ឃើញថា** មានកាលៈទេសៈផ្សេងៗដែលអាចឱ្យក្រុមប្រឹក្សាជំនុំជម្រះពិសេសចេញសេចក្តីសម្រេចរបស់ខ្លួនត្រង់ផ្នែកសេចក្តីសម្រេចទៅលើបណ្តឹងជំទាស់នៅក្នុងដំណាក់កាលនេះ ដោយផ្តល់សំអាងហេតុពេញលេញជាភាសាខ្មែរ អង់គ្លេស និងបារាំង ឱ្យបានឆាប់រហ័សនៅពេលក្រោយនោះ។

**ហេតុដូច្នេះ ក្រុមប្រឹក្សាជំនុំជម្រះពិសេសសម្រេច ÷**

ជាឯកច្ឆ័ន្ទ **ទទួល** ពាក្យបណ្តឹងរបស់ ខៀវ សំផន ពាក្យបណ្តឹងរបស់ នួន ជា និងពាក្យបណ្តឹងជំទាស់សាជាថ្មីរបស់ ខៀវ សំផន អនុលោមតាមវិធាន ៣៤ (៤) នៃវិធានផ្ទៃក្នុង។

ជាឯកច្ឆ័ន្ទ **បដិសេធ** ខ្លឹមសារនៃពាក្យបណ្តឹងរបស់ ខៀវ សំផន ចំពោះចៅក្រម Claudia FENZ។

តាមមតិភាគច្រើនដោយមានចៅក្រមបួនរូប (ហើយចៅក្រម Rowan DOWNING មានមតិជំទាស់) **បដិសេធ** ខ្លឹមសារនៃពាក្យបណ្តឹងរបស់ ខៀវ សំផន ចំពោះចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះ ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc LAVERGNE និងចៅក្រម យូរ ឧត្តរា។

តាមមតិភាគច្រើនដោយមានចៅក្រមបួនរូប (ហើយចៅក្រម Rowan DOWNING មានមតិជំទាស់) **បដិសេធ** ខ្លឹមសារនៃពាក្យបណ្តឹងរបស់ នួន ជា។

អនុលោមតាមវិធាន ៣៤(៨) នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចនេះបិទផ្លូវតវ៉ា។

ភ្នំពេញ ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១៤

ឆូ មណី

Rowan Downing

ហួត វុទ្ធី

Chang-ho Chung

ប្រាក់ គឹមសាន